# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧៧...សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារសម្រាប់ធ្វើការសិក្សា អំពីគំរោងបង្កើតពន្ធលើដី និងលំនៅដ្ឋាន នៅរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមស្មារតីសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៥

## សម្រេច

**ប្រការ ១.-** ត្រូវបានបង្កើតក្រុមការងារសម្រាប់ធ្វើការសិក្សា អំពីគំរោងបង្កើតពន្ធលើដី និងលំនៅដ្ឋាន នៅរាជធានីភ្នំពេញ ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ប៊ុន អ៊ុយ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **អ៊ុង ច័ន្ទជាវិន្ទ** | សមាជិក ក.ស.ស.ស | អនុប្រធាន |
| ៣- ឯកឧត្តម | **ស្វូង ម៉េងគា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- ឯកឧត្តម | **សន ស៊ីថន** | នាយកវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | សមាជិក |
| ៥- ឯកឧត្តម | **តូ លីទុន្ស** | អគ្គលេខាធិការអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា គមនាគមន៍ ពត៌មានវិទ្យា | សមាជិក |
| ៦- លោក | **ហុង ថា** | មន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | | |
|---|---|---|---|
| ៧- លោក | **ឆាំ សុជាតិវង្ស** | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |
| ៨- លោក | **ស៊ឹម អឿន** | ប្រធាននាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- លោក | **ឆាយ ឫទ្ធិសែន** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ | សមាជិក |
| ១០- លោក | **តែ ប៊ុណ្ណារិទ្ធ** | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងធនាគារនៃទីស្តីការគណៈរដ្ឋមន្ត្រី | លេខាធិការ |

**ប្រការ** ២.-ក្រុមការងារនេះមានភារកិច្ចសិក្សាស្រាវជ្រាវអំពីលទ្ធភាពបង្កើនចំណូលចូលថវិកាជាតិ តាមរយៈការបង្កើតពន្ធលើដី និងលំនៅដ្ឋាននៅរាជធានីភ្នំពេញដោយ ÷

-សិក្សាស្រាវជ្រាវអំពីគោលនយោបាយ និង វិធីសាស្ត្រសម្រាប់ត្រៀមរៀបចំការប្រមូលចំណូលពន្ធលើដី និងលំនៅដ្ឋានដោយបែងចែកប្រភេទពន្ធ និងមុខសញ្ញាត្រូវប្រមូលពន្ធ

-សិក្សាស្រាវជ្រាវអំពីការអនុវត្តពន្ធលើដី និងលំនៅដ្ឋាន នៅបណ្តាប្រទេសអាស៊ាន និងបណ្តាប្រទេសដទៃទៀត ដើម្បីដកយកបទពិសោធន៍រៀបចំគោលនយោបាយ និងនីតិវិធីដាក់ស្តែងសម្រាប់អនុវត្តសាកល្បងជាជំហានដំបូងនៅរាជធានីភ្នំពេញ

-ចងក្រងអត្ថបទស្តីពីគោលនយោបាយ និងនីតិវិធីលើការប្រមូលពន្ធលើដី និងលំនៅដ្ឋាននៅរាជធានីភ្នំពេញ ដោយលើកអនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាលតាមរយៈ ប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ និងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ** ៣.-សមាជិកក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ** ៤.-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ និងសាមីខ្លួន ក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច និង ឯកឧត្តម ឧបនាយរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ